**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៩៧/២៦/២០១៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣

**ជម្រាបមក**

**លោក លី សុភ័ណ្ឌ**

ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៧០១B ផ្លូវជាតិលេខ២ ភូមិក្រពើហាកើត សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល

**កម្មវត្ថុ** : ប្ដឹងជំទាស់លិខិតលេខ ៨១១/១៣ គ.ជ.ប ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**យោង** :
- ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥
- ពាក្យបណ្ដឹងរបស់លោក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតលេខ ៨១១/១៣ គ.ជ.ប ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្ដឹងរបស់លោក និង បានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ចំពោះបណ្ដឹងរបស់លោកនេះ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចទទួលយកមកពិនិត្យដោះស្រាយបានទេ ពីព្រោះ ៖

-រូបលោកជាម្ចាស់បណ្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញបានទទួលការផ្ទេរសិទ្ធិពីឈ្មោះ **ជា ធី** ដែលឈ្មោះនេះគ្មានជាប់ពាក់ព័ន្ធក្នុងសំណុំរឿងនៃលិខិតលេខ ៨១១/១៣ គ.ជ.ប ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ

-កម្មវត្ថុបណ្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញពុំត្រូវគ្នានឹងអង្គហេតុរៀបរាប់ក្នុងបណ្ដឹងនៅថ្នាក់ដំបូងទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh